ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានរតនាគារជាតិ
នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាននិងសរុបស្ថិតិ

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**I-លទ្ធផលការងារដែលបានអនុវត្តក្នុងកក្កដា ឆ្នាំ២០១៨÷**

អគ្គនាយកដ្ឋានរតនាគារជាតិបានអនុវត្តការងារក្នុងខែកក្កដា ឆ្នាំ២០១៨ មួយចំនួនដូចខាងក្រោម÷

១-បានជំរុញលើការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ របបសន្តិសុខសង្គមរបស់និវត្តជន(បជស) និងបេឡាជាតិអតីតយុទ្ធជន(បជអ) បានទាន់ពេលវេលា។

២-បានចូលរួមប្រជុំ ស្តីពីវឌ្ឍនភាពនៃការអនុវត្តថវិកា **ផអ៣** ឆ្នាំ២០១៨។

៣-បានចូលរួមប្រជុំ ស្តីពីការរៀបចំឯកសារតម្រង់ទិសបញ្ជីមុខសញ្ញាចំណាយគម្រោងសេវាសង្គម របស់រដ្ឋបាលរាជធានី ខេត្ត។

៤-បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេស ស្តីពី“ការពិភាក្សាពិនិត្យលទ្ធភាពក្នុងការធ្វើសន្ទានកម្មស្ថិតិហិរញ្ញវត្ថុ (GFS) ជាមួយប្រព័ន្ធ FMIS”។

៥-បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេស ស្តីពី “ការពិភាក្សានិងប្រមូលធាតុចូលបន្ថែមក្នុងការជ្រើសរើសគ្រឹះស្ថានសាធារណៈរដ្ឋបាលក្នុងការរៀបចំស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS)”។

៦-បានបន្តប្រជុំណែនាំមន្ត្រីជំនាញ ទទួលបន្ទុកពិនិត្យការអនុវត្តចំណាយថវិកា ស្តីពីលិខិតបទដ្ឋានគតិយុត្ត ដែលបានធ្វើបច្ចុប្បន្នភាពថ្មីៗ ដើម្បីពង្រឹងគុណភាព ប្រសិទ្ធភាពក្នុងការត្រួតពិនិត្យអាណត្តិបើកប្រាក់ លិខិតយុត្តិការចំណាយ និងដើម្បីទូទាត់ចំណាយថវិកាឱ្យបានទាន់ពេលវេលា ហើយបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ។

៧-បានបន្តជំរុញក្រសួង ស្ថាប័ន ឱ្យរៀបចំរបាយការណ៍សម្រេចទូទាត់ឆ្នាំ២០១៧ ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

៨-បានបន្តជំរុញដល់រតនាគាររាជធានី ខេត្ត ឱ្យពង្រឹងគុណភាពរបាយការណ៍ចំណាយថវិកា ឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា។

៩-បានប្រមូលសរុបយោបល់របស់អគ្គនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើផ្នែកនៃការវិភាគនិងការវាយតម្លៃការអនុវត្តចំណូល ចំណាយថវិកា និងស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៧ នៃសេចក្តីព្រាងអត្ថបទកំណត់បង្ហាញនៃច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។

១០-បានបន្តសហការជាមួយក្រសួង ស្ថាប័នថវិកាកម្មវិធីក្នុងការដោះស្រាយបញ្ហាប្រឈម ដែលពាក់ព័ន្ធនឹងការអនុវត្តចំណាយថវិកា ជាពិសេសលើការអនុវត្តចំណាយរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធី។

១១-បានបន្តធ្វើការជាមួយក្រុមការងារ ITD ដើម្បីរៀបចំរបាយការណ៍ចំណាយថវិកាចេញពីប្រព័ន្ធ FMIS ជាពិសេសរបាយការណ៍ចំណាយថវិកាសម្រាប់បម្រើ ដល់ការរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ ដែលនៅមានបញ្ហាបច្ចេកទេសមិនទាន់មានគុណភាពអាចប្រើប្រាស់បាននៅឡើយ។

១២-បានចូលរួមប្រជុំពិភាក្សា ស្តីពីនីតិវិធីនៃកិច្ចបញ្ជិកាចំណូល ចំណាយសោធននិវត្តន៍របស់បេឡាជាតិសន្តិសុខសង្គមសម្រាប់ មន្ត្រីរាជការស៊ីវិលនិងបេឡាជាតិអតីតយុទ្ធជនសម្រាប់ឆ្នាំ២០១៩ និងពិនិត្យសេចក្តីព្រាងប្រកាសស្តីពីការបន្ថែមអនុគណនី ចំណូលចំណាយថវិកា នៃចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

១៣-បានចូលរួមប្រជុំពិភាក្សា ស្ដីពីការបង្កើតបន្ថែមអនុគណនីចំណូល និងអនុគណនីចំណាយថ្មី សម្រាប់បេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិអតីតយុទ្ធជន និងបេឡាជាតិសន្តិសុខសង្គម។

១៤-បានចូលរួមប្រជុំពិភាក្សា និងដោះស្រាយបញ្ហា លើការកត់ត្រាចំណូលមិនឆ្លងកាត់រតនាគារក្នុងឆ្នាំ២០១៧ ដែលត្រូវធ្វើសន្ធានកម្មចូលក្នុងប្រព័ន្ធ FMIS។

១៥-បានចូលរួមកិច្ចប្រជុំពិភាក្សា ស្ដីពីការពិនិត្យលទ្ធភាពក្នុការធ្វើសន្ធានកម្មស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ជាមួយប្រព័ន្ធ FMIS។

១៦-បានចូលរួមធ្វើតេស្តរបាយការណ៍ចំណូល ចំណាយសាច់ប្រាក់ (R09) នៅក្នុងប្រព័ន្ធ FMIS។

១៧-បានធ្វើតេស្តរបាយការណ៍ R37 (តារាង "ក") និងផ្ទៀងផ្ទាត់តួលេខឆ្នាំ២០១៦ និង២០១៧បានត្រឹមត្រូវ។ដោយឡែកសម្រាប់តួលេខ ឆ្នាំ២០១៨ នៅពុំទាន់បានធ្វើតេស្តនៅឡើយទេ។

១៨-បានរៀបចំសេចក្ដីណែនាំ ស្ដីពីការប្រើប្រាស់គណនីចំណាយថវិកាសេវាសង្គមរបស់រដ្ឋបាលរាជធានីខេត្ត។

១៩-បានរៀបចំបន្តកិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ស្ដីពីការបែងចែកចំណូលពន្ធ និងចំណូលពន្ធលើអចលនទ្រព្យជូនរដ្ឋបាលថ្នាក់ក្រោមជាតិ។

២០-បានចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីគណនីទោលរបស់អគ្គនាយកដ្ឋានរតនាគារជាតិ នៅប្រទេសបារាំង។

២១-បានចូលរួមកិច្ចប្រជុំពិភាក្សា អំពីលំហូរថវិកា និងការបង្កើតបន្ថែមអនុគណនីចំណាយថវិកា និងអនុគណនីចំណូលថវិការបស់ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (បជស) និងបេឡាជាតិអតីតយុទ្ធជន(បជអ) ជាមួយតំណាងនាយកដ្ឋានហិរញ្ញកិច្ច តំណាងអគ្គនាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំនៅបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (បជស) និងបេឡាជាតិអតីតយុទ្ធជន (បជអ)។

២២-បានរៀបចំលិខិតស្នើសុំគោលការណ៍អនុវត្ត ស្ដីពីលំហូរថវិកាបិទកិច្ចបញ្ជិកាគណនេយ្យរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (បជស) និងបេឡាជាតិអតីតយុទ្ធជន (បជអ) នៅឆ្នាំ២០១៩។

២៣-បានរៀបចំប្រកាសបំពេញបន្ថែមអនុគណនីមួយចំនួន លើប្រកាសលេខ ១២១២ និងប្រកាសលេខ ៥២៣។

២៤-ក្រុមការងារអធិការកិច្ចបានចុះពិនិត្យកិច្ចបញ្ជិកាគណនេយ្យ សម្រាប់ការិយបរិច្ឆេទ២០១៧ និងបណ្ដាឆ្នាំពាក់ព័ន្ធនៅរតនាគារខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តស្ទឹងត្រែង ។

២៥-គណៈកម្មការជម្រះចោលឯកសារអស់សុពលភាពប្រើប្រាស់បានចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ដើម្បីកម្ទេចឯកសារដែលអស់សុពលភាពប្រើប្រាស់ឆ្នាំ២០០៦ នៅរតនាគារខេត្តកំពង់ធំ។

## II-ទិសដៅសម្រាប់អនុវត្តការងារខែសីហា ឆ្នាំ២០១៨÷

អគ្គនាយកដ្ឋានរតនាគារជាតិមានទិសដៅសម្រាប់អនុវត្តការងារខែសីហា ឆ្នាំ២០១៨មានដូចខាងក្រោម÷

១-ត្រូវបន្តជំរុញលើការបើកផ្ដល់ប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឱ្យបានទាន់ក្នុងខែ។

២-បន្តជំរុញរតនាគាររាជធានី ខេត្ត ឱ្យបន្តពង្រឹងគុណភាពរបាយការណ៍ចំណាយថវិកា ឱ្យបានត្រឹមត្រូវនិងទាន់ពេលវេលា។

៣-បន្តបំប៉នសមត្ថភាពការងាររបស់មន្ត្រីជំនាញ លើការត្រួតពិនិត្យការអនុវត្តចំណាយថវិកា ឱ្យបានត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ និងស្របតាមបច្ចុប្បន្នភាពនៃលិខិតបទដ្ឋានគតិយុត្តិ។

៤-បន្តណែនាំនិងបណ្ដុះបណ្ដាលក្រសួង ស្ថាប័ន និងអង្គភាពថវិកាលើការងារពាក់ព័ន្ធនឹងការអនុវត្តចំណាយតាមរជ្ជទេយ្យបុរេប្រទាន និងចំណាត់ថ្នាក់ទាំង៧នៃមាតិកាថវិកា។

៥-បន្តរៀបចំឯកសារពាក់ព័ន្ធ និងសេចក្ដីព្រាងច្បាប់ទូទាត់ថវិកាឆ្នាំ២០១៧ ដើម្បីរៀបចំកិច្ចប្រជុំក្រុមការងារ ក.ច.ទ លើកទី១។

៦-បន្តសហការជាមួយក្រុមការងារ ITD ដើម្បីរៀបចំរបាយការណ៍ចំណាយថវិកាចេញពីប្រព័ន្ធ FMIS ជាពិសេសរបាយការណ៍សម្រាប់បម្រើដល់ការរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

៧-បន្តជម្រុញការដោះស្រាយបញ្ហាមួយចំនួន អំពីការប្រើប្រាស់ប្រព័ន្ធ NRMIS។

៨-បន្តសហការក្នុងការងារធ្វើសវនកម្មលើឯកសារចំណូលឆ្នាំ២០១៧ របស់អង្គភាពសវនកម្មផ្ទៃក្នុង និងសវនកម្មជាតិ។

៩-រៀបចំសេចក្តីណែនាំ ស្តីពីកិច្ចបញ្ជិកាចំណូលជាប្រាក់ដុល្លារនៅតាមរាជធានី ខេត្ត។

១១-រៀបចំសេចក្តីណែនាំ ស្តីពីការបំពេញអាណត្តិបើកប្រាក់(អាណត្តិផ្ទេរក្នុង) របស់គ្រឹះស្ថានសាធារណរដ្ឋបាល។

១២-រៀបចំសេចក្តីណែនាំ ស្តីពីការប្រើប្រាស់មាតិកាចំណូល ចំណាយថវិកា លើសេវាកម្មសង្គមរបស់រដ្ឋបាលរាជធានី ខេត្ត។

១៣-បន្តកិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការបែងចែកចំណូលពន្ធលើឈ្នួលអចលនទ្រព្យ ជូនរដ្ឋបាលថ្នាក់ក្រោមជាតិ។

១៤-អធិការកិច្ចរតនាគារ ត្រូវចុះត្រួតពិនិត្យការងាររតនាគាររាជធានី ខេត្តសម្រាប់ការិយបរិច្ឆេទ២០១៧ និងបណ្តាឆ្នាំពាក់ព័ន្ធជាបន្តបន្ទាប់ទៀត។

១៥-គណៈកម្មការជម្រះចោលឯកសារអស់សុពលភាពប្រើប្រាស់ ត្រូវបន្តចុះដុតកម្ទេចឯកសារឆ្នាំ២០០៦ នៅតាមបណ្តារតនាគារខេត្តជាបន្តទៀត។